06 DEC 2013 H6:00-3037

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ : ...អា.ជ.ប.ជ.អ.

ភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣

គោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ : សំណើសុំរាជរដ្ឋាភិបាលចេញគោលការណ៍ ៧ ចំណុចក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ។

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់ជម្រាបជូនសម្តេចតេជោ មេត្តាជ្រាបថា រហូតមកដល់ពេលនេះ អត្រាចម្លងមេរោគអេដស៍ក្នុងចំណោមប្រជាពលរដ្ឋអាយុពី ១៥ ទៅ ៤៩ ឆ្នាំ បានធ្លាក់ចុះពី ០,៨% នៅឆ្នាំ ២០១១ មក ០,៧% នៅឆ្នាំ ២០១២ និង ២០១៣ ចំណែកឯការផ្តល់សេវាព្យាបាលដោយឱសថដល់អ្នកជំងឺអេដស៍ មានរហូតដល់ ៨៥% ដោយយើងសង្ឃឹមថា អត្រានេះ អាចឈានដល់ ១០០% នៅឆ្នាំ ២០១៤ ខាងមុខ ។ ទាំងនេះ ជាជោគជ័យមួយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាយើង បានទទួលការកោតសរសើរពីសំណាក់ដៃគូអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ និង ប្រទេសជាមិត្តជាច្រើន ។

ជាមួយគ្នានេះ យើងក៏ជួបប្រទះនូវភាពប្រឈមមួយចំនួនដូចជា ស្ត្រីបំរើសេវាកំសាន្ត ឬ សេវាកម្មភេទ (EW) មានអត្រាឆ្លងមេរោគអេដស៍ ១៤% បុរសស្រឡាញ់បុរស (MSM) មាន ២% ចំណែកឯអ្នកញៀនគ្រឿងញៀនប្រើម្ជុល (IDU) អាចមានរហូតដល់ ២៤% ។ ម្យ៉ាងទៀត ការប្រើស្រោមអនាម័យក៏មាននិន្នាការធ្លាក់ចុះ ដោយអ្នករួមភេទជាលក្ខណៈដៃគូមានការធ្វេសប្រហែស និង ជឿថា មេរោគអេដស៍មិនកាចសាហាវដូចមុនទៀតទេ ។ ប្រការដែលគួរឲ្យបារម្ភជាងគេនោះ គឺ ភាពស៊ាំនឹងជំងឺដោយសារអ្នកជំងឺមិនបានទទួលការព្យាបាលឲ្យបានទៀងទាត់ ជាពិសេស អ្នកផ្លូវមេរោគអេដស៍ដែលធ្វើចំណាកស្រុក ។ ជនចំណាកស្រុកទាំងនោះ ធ្លាប់ទទួលសេវាព្យាបាលក្នុងស្រុក ក៏ប៉ុន្តែនៅពេលទៅរស់នៅបរទេស ក៏ដាច់ការព្យាបាល ។ ពេលអ្នកទាំងនោះ ត្រឡប់មករកសេវាព្យាបាលក្នុងប្រទេសវិញ អ្នកជំងឺមានភាពស៊ាំនឹងជំងឺ ឯមេរោគក៏កាចសាហាវជាងមុនដែរ ។ ក្នុងករណីនេះ ការព្យាបាលក៏មានការលំបាក ឯតម្លៃក៏មានតម្លៃខ្ពស់រហូតអាចឡើងដល់ ១០០ ដង លើសមុនទៀតផង ។

កត្តាសង្គមដែលមានការផ្លាស់ប្តូរឥតឈប់ឈរ ដោយសារការរីកចំរើននៃព័ត៌មានវិទ្យា បានធ្វើឲ្យទំនាក់ទំនងរវាងបុរស និង ស្ត្រី ជាពិសេស ក្នុងចំណោមយុវវ័យ មានការងាយស្រួលឆាប់រហ័ស ឯ

ការរួមភេទក៏ប្រព្រឹត្តដោយមិនសូវគិតគូរដល់ផលវិបាក ដូចជាដល់ការចម្លងកាមរោគ ឬ ជំងឺអេដស៍ ឬ មានកូនមុនពេលចង់បានជាដើម ។ល។ យុវវ័យ ក៏ស្ថាយទៅជាមុខសញ្ញានៃការចម្លងកាមរោគ និង មេរោគអេដស៍ ដែលរាជរដ្ឋាភិបាលយើង ត្រូវយកចិត្តទុកដាក់ជាអាទិភាពខ្ពស់ ។ ក្រៅពីយុវជន-យុវនារី ងាយរងគ្រោះនោះ យើងក៏ត្រូវគិតគូរដល់កុមារកំព្រាដែលឪពុក ម្តាយ ស្លាប់ដោយជំងឺអេដស៍ ដែលឥឡូវនេះ ខ្លះក៏ស្ថិតនៅជាយុវវ័យដែលត្រូវទទួលការអប់រំ បំពាក់បំប៉នវិជ្ជាជីវៈ ដើម្បីជីវភាពរស់នៅផ្ទាល់ខ្លួនរបស់ពួកគេ ។

ការរើសអើង និង ការអៀនខ្មាស់ដោយជំងឺអេដស៍ ក៏នៅតែជាកត្តាកំងស្ទះដល់ការផ្តល់សេវាព្យាបាលគ្រប់ប្រភេទដល់អ្នកផ្ទុកមេរោគអេដស៍ ។

តាមការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ អត្រាចម្លងថ្មីនៃមេរោគអេដស៍ អាចនឹងបន្តចុះថយតទៅទៀត គឺ មានថយពីចំនួនប្រហែល ១.០០០នាក់ នៅឆ្នាំ ២០១៣ ទៅនៅត្រឹម ៩០០ នាក់ នៅឆ្នាំ ២០១៥ ក្នុង ១ ឆ្នាំ ។ ក៏ប៉ុន្តែ ចំនួនអ្នកស្លាប់ដោយជំងឺអេដស៍ អាចកើនឡើងពី ២.២០០នាក់ នៅឆ្នាំ ២០១៣ ទៅ ២.៣០០នាក់ នៅឆ្នាំ ២០១៥ ក្នុង ១ ឆ្នាំ ។

អាស្រ័យហេតុនេះ ដើម្បីឲ្យព្រះរាជាណាចក្រកម្ពុជាយើង អាចឈានទៅសម្រេចគោលដៅបីសូន្យខាងលើ ខ្ញុំបានស្នើសុំរាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយ ៧ ចំណុច ដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ដូចខាងក្រោម ៖

១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តសហការជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិលផង ជំរុញ និង លើកទឹកចិត្តឲ្យមានការប្រើស្រោមអនាម័យឲ្យបាន ១០០% ដើម្បីសុវត្ថិភាពក្នុងការរួមភេទ ឲ្យរួចផាកការឆ្លងកាមរោគ និង មេរោគអេដស៍ ។

២. បញ្ចូលការប្រយុទ្ធនឹងជំងឺអេដស៍ និង សុខភាពមាតា ជាចំណុចបន្ថែមនៃគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល និង ក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល ត្រូវសហការគ្នារៀបចំផែនទីបញ្ជាក់ពីភូមិសាស្ត្រ-ចំនួន-អ្នកផ្ទុកមេរោគអេដស៍-ក្រុមជនងាយរងគ្រោះមាន ៖ នារីបំរើសេវាកំសាន្ត-បុរសស្រឡាញ់បុរស-កុមារកំព្រាដែលឪពុកម្តាយស្លាប់ដោយជំងឺអេដស៍-ជនចំណាកស្រុក ដែលផ្ទុកមេរោគអេដស៍ ចំនួន និង ទីកន្លែង មន្ទីរផ្តល់សេវាព្យាបាលជំងឺអេដស៍ ។

៤. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវចាត់វិធានការធ្វើឲ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំរាជធានី ខេត្ត ក្រុង ស្រុក ឃុំ/សង្កាត់ មានសកម្មភាពឡើងវិញ ។ ក្រសួងសុខាភិបាល ត្រូវណែនាំដល់មន្ទីរសុខាភិបាលខេត្តនីមួយៗ ឲ្យសហការជិតស្និទ្ធជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខេត្ត ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ ។ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត

នីមួយៗ ត្រូវពង្រឹងលក្ខណៈជាដៃគូជាមួយអង្គការសង្គមស៊ីវិល ដែលកំពុងដំណើរការនៅក្នុងខេត្ត របស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ។

៥. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និង បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវសហការគ្នា ដើម្បីអនុញ្ញាតឲ្យជនងាយរងគ្រោះដោយជំងឺអេដស៍ ដែលមានជាអាទិ៍ នារីបំពេីសេវាកំសាន្ត បុរសស្រឡាញ់បុរស អ្នកញៀនគ្រឿងញៀនប្រើម្ជុល អាចទទួលបានសេវាព្យាបាលជំងឺអេដស៍បានយ៉ាងទូលំទូលាយ ។

៦. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា អង្គការយុវជន ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនការអប់រំដល់យុវជន-យុវនារី ឲ្យយល់ដឹងពីគ្រោះថ្នាក់នៃជំងឺអេដស៍ និង វិធីបង្ការ ការពារឲ្យបានទូលំទូលាយ ។

៧. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទីដឹកនាំសំរបសំរួល និង តាមដានការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ស្របតាមការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមុខនាទីដឹកនាំ និង ទទួលខុសត្រូវលើប្រសិទ្ធភាពនៃជំនួយសំរាប់ការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍ទូទាំងប្រទេស ។ ក្រសួងមន្ទីរពាក់ព័ន្ធ រាជធានី និង ខេត្ត ត្រូវសហការគ្នារៀបចំកម្មវិធីការងារប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីកែសម្រួសការប្រើប្រាស់ធនធាន ដែលបានទទួលពីគ្រប់មជ្ឈដ្ឋាន ឲ្យបានលទ្ធផលជាក់ស្តែង ប្រសិទ្ធភាព ប្រសិទ្ធិផល និង ឈានទៅធានានិរន្តរភាព ។

ខ្ញុំបាទមានជំនឿថា ប្រសិនបើរាជរដ្ឋាភិបាលយើងអនុវត្តតាមគោលនយោបាយទាំង ៧ ចំណុចនេះ ព្រះរាជាណាចក្រកម្ពុជា អាចសម្រេចបាននូវគោលដៅបីសូន្យខាងលើគឺ៖ សូន្យការឆ្លងថ្មីនៃមេរោគអេដស៍ សូន្យការរើសអើង សូន្យគ្មានការស្លាប់ដោយមេរោគអេដស៍ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមសម្តេចតេជោ មេត្តាពិនិត្យ និង អនុញ្ញាតឲ្យចេញនូវគោលនយោបាយ ៧ ចំណុចរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ដោយក្តីអនុគ្រោះបំផុត ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ ។

ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស
និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឈឿន ឬទ្ធី